# ក្លាយដូចជាក្មេងតូចៗ

ជីន អេ ស្ទីវិន
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានអង្គការបឋមសិក្សាទូទៅ

*បើយើងមានដួងចិត្តចង់រៀន និងមានឆន្ទៈដើម្បីធ្វើតាមគំរូនៃក្មេងៗ នោះលក្ខណៈដ៏ទេវភាពរបស់គេ អាចជាកូនសោដើម្បីចាក់បើកការលូតលាស់ខាងវិញ្ញាណរបស់យើង ។*

ក្នុងសេចក្ដីប្រាជ្ញា និងក្នុងសេចក្ដីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់យើង បានបញ្ជូនវិញ្ញាណនៃបុត្រាបុត្រីរបស់ទ្រង់មកកាន់ផែនដីនេះជាកូនក្មេង ។ ពួកគេកើតក្នុងគ្រួសារទាំងឡាយដែលជាអំណោយដ៏ថ្លៃថ្លាជាមួយនឹងលក្ខណៈ និងជោគវាសនាដ៏ទេវភាព ។ ព្រះវរបិតាសួគ៌របស់យើងទ្រង់ជ្រាបថា ក្មេងតូចៗគឺជាឧបករណ៍ក្នុងការជួយយើងឲ្យប្រែក្លាយដូចជាទ្រង់ ។ មានអ្វីជាច្រើនដែលយើងអាចរៀនពីក្មេងៗទាំងនោះ ។

ការពិតដ៏សំខាន់នេះត្រូវបានផ្ដល់ភស្តុតាងជាច្រើនឆ្នាំមកហើយ នៅពេលសមាជិកម្នាក់នៃពួកចិតសិបត្រូវបានចាត់តាំងទៅក្រុងហុងកុង ។ គាត់បានទៅកាន់វួដដ៏រាបទាបមួយដែលមានការពិបាកជាច្រើន ហើយមិនអាចផ្គត់ផ្គង់តម្រូវការរបស់ខ្លួនបាននោះទេ ។ ពេលដែលប៊ីស្សពពណ៌នាពីស្ថានភាពរបស់ពួកគេ អ្នកដឹកនាំទូទៅរូបនោះបានមានចំណាប់អារម្មណ៍ថា ត្រូវឲ្យសមាជិកបង់ដង្វាយមួយភាគដប់របស់ខ្លួន ។ ដោយដឹងពីកាលៈទេសៈដ៏ធ្ងន់ធ្ងររបស់ពួកគេ ប៊ីស្សពបានមានការព្រួយបារម្ភថាតើគាត់ត្រូវផ្ដល់ដំបូន្មាននោះដោយរបៀបណាទៅ ។ គាត់បានគិតពីបញ្ហានោះ ហើយសម្រេចចិត្តថា គាត់នឹងនិយាយទៅកាន់សមាជិកទាំងឡាយណាដែលមានជំនឿខ្លាំងបំផុតក្នុងវួដរបស់គាត់ ហើយសុំឲ្យពួកគេបង់ដង្វាយមួយភាគដប់របស់ពួកគេ ។ ថ្ងៃអាទិត្យបន្ទាប់ គាត់បានទៅកាន់ថ្នាក់កុមារ ។ គាត់បានបង្រៀនក្មេងៗពីច្បាប់ដង្វាយមួយភាគដប់របស់ព្រះអម្ចាស់ ហើយបានសួរថាតើពួកគេនឹងមានឆន្ទៈក្នុងការបង់ដង្វាយមួយភាគដប់ពីប្រាក់ដែលគេរកបានឬទេ ។ ក្មេងៗបាននិយាយថា ពួកគេនឹងធ្វើ ។ ហើយពួកគេបានធ្វើមែន ។

ក្រោយមក ប៊ីស្សពបានទៅកាន់សមាជិកពេញវ័យក្នុងវួដ ហើយបានចែកចាយជាមួយពួកគេថា អស់រយៈពេលប្រាំមួយខែចុងក្រោយនេះ ក្មេងៗដ៏ស្មោះត្រង់របស់ពួកគេបានបង់ដង្វាយមួយភាគដប់ ។ គាត់បានសួរពួកគេ បើពួកគេនឹងមានឆន្ទៈក្នុងការធ្វើតាមគំរូក្មេងៗទាំងនេះ ហើយធ្វើដូចគ្នាដែរ ។ សមាជិកទាំងនោះបានរំជួលនៅក្នុងចិត្តដោយការលះបង់ដ៏ចាំបាច់ដែលក្មេងៗបានធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីបង់ដង្វាយមួយភាគដប់របស់ខ្លួន ។ ហើយបង្អួចនៃស្ថានសួគ៌ត្រូវបានបើក ។ ដោយគំរូរបស់ក្មេងៗដ៏ស្មោះត្រង់ទាំងនេះ ធ្វើឲ្យវួដរីកចម្រើនក្នុងការគោរពប្រតិបត្តិ និងទីបន្ទាល់ ។

ព្រះយេស៊ូវគ្រីស្ទ ទ្រង់គឺជាអង្គដែលបានបង្រៀនយើងឲ្យមើលទៅក្មេងៗជាគំរូ ។ ព្រះគម្ពីរសញ្ញាថ្មីមានកត់ត្រាចម្លើយរបស់ទ្រង់ ពេលដែលសាវករបស់ទ្រង់ជជែកគ្នាថា តើនរណាជាអ្នកដែលធំជាងគេនៅក្នុងនគរស្ថានសួគ៌ ។ ព្រះយេស៊ូវ បានឆ្លើយសំណួររបស់ពួកគេជាមួយនឹងមេរៀនដ៏តូចមួយ ប៉ុន្តែវាពោរពេញទៅដោយខ្លឹមសារ ។ ទ្រង់បានហៅក្មេងតូចមួយមកកាន់ទ្រង់ ហើយបានដាក់ក្មេងនោះនៅកណ្ដាលពួកគេ រួចមានព្រះបន្ទូលថា ៖« បើអ្នករាល់គ្នាមិនផ្លាស់គំនិត ហើយត្រឡប់ដូចជាកូនតូចនេះ នោះនឹងចូលនគរស្ថានសួគ៌ពុំបានឡើយ ។ អ្នកណាដែលបន្ទាបខ្លួន ឲ្យបានដូចកូនតូចនេះ អ្នកនោះឯងឈ្មោះថា ធំជាងគេក្នុងនគរស្ថានសួគ៌ហើយ »
( ម៉ាថាយ 18:3–4 ) ។

តើអ្វីខ្លះដែលយើងត្រូវរៀនពីក្មេងៗ ? តើគុណសម្បត្តិ និងគំរូអ្វីខ្លះដែលគេបានបង្ហាញអាចជួយយើងក្នុងការអភិវឌ្ឍន៍ខាងវិញ្ញាណរបស់យើងផ្ទាល់ ?

ក្មេងៗដ៏មានតម្លៃរបស់ព្រះបានមកកាន់យើងដោយដួងចិត្តជឿជាក់ ។ ពួកគេពេញដោយសេចក្ដីជំនឿ និងងាយទទួលអារម្មណ៍នៃព្រះវិញ្ញាណ ។ ពួកគេធ្វើជាគំរូនៃការបន្ទាបខ្លួន ការគោរព និងសេចក្ដីស្រឡាញ់ ។ ជាញឹកញាប់ ពួកគេជាអ្នកទីមួយដែលស្រឡាញ់ និងអភ័យទោស ។

សូមឲ្យខ្ញុំចែកចាយបទពិសោធន៍ខ្លះៗពីរបៀបដែលក្មេងៗអាចផ្ដល់ពរជ័យដល់ជីវិតរបស់យើងជាមួយនឹងគំរូនៃលក្ខណៈដូចព្រះគ្រីស្ទរបស់ពួកគេ ដែលគ្មានកំហុស ប៉ុន្តែពោរពេញដោយឥទ្ធិពល ។

ថត ជាក្មេងប្រុសតូចអាយុទើបតែពីរឆ្នាំថ្មីៗនេះ បានទៅសារមន្ទីរសិល្បៈ ជាមួយនឹងម្ដាយខ្លួន ដែលកំពុងតែមានការតាំងពិព័រណ៌ពិសេសមួយពីគំនូរដ៏ស្រស់ស្អាតអំពីព្រះអង្គសង្គ្រោះ ។ កាលដែលពួកគេបានដើរកាត់រូបភាពដ៏ពិសិដ្ឋទាំងនោះ គាត់បានឮកូនតូចរបស់គាត់និយាយព្រះនាម « ព្រះយេស៊ូវ »

ដោយគារវភាព ។ គាត់បានងាកមើលកូនគាត់ ហើយបានឃើញ ថត កំពុងតែឱបដៃ និងឱនក្បាល នៅពេលដែលវាមើលរូបគំនូរទាំងឡាយ ។ តើយើងអាចរៀនពី ថត នូវឥរិយាបថនៃការបន្ទាបខ្លួន នៃគារវភាព និងនៃក្តីស្រឡាញ់សម្រាប់ព្រះអម្ចាស់បានទេ ?

កាលពីរដូវស្លឹកឈើជ្រុះមុននេះ ខ្ញុំបានមើលពីគំរូនៃក្មេងប្រុសអាយុដប់ឆ្នាំ នៅប្រទេសអាមេនី ។ កាលដែលយើងបានរង់ចាំការប្រជុំសាក្រាម៉ង់ចាប់ផ្តើម គេបានកត់សម្គាល់ពីការមកដល់របស់សមាជិកវ័យចំណាស់បំផុតនៅក្នុងសាខា ។ គេជាម្នាក់ដែលទៅជិតគាត់ភ្លាមៗ ហើយបានហុចដៃរបស់គេដើម្បីទប់ដំណើរយោលយោគរបស់គាត់ ។ គេបានជួយនាំគាត់ទៅកាន់កៅអីជួរមុខគេ ជាកន្លែងដែលគាត់អាចស្តាប់ឮ ។ តើទង្វើល្អដ៏តូចរបស់គេអាចបង្រៀនយើងទេថា អ្នកដែលធំជាងគេបំផុតក្នុងនគរនៃព្រះ -អម្ចាស់ គឺអ្នកដែលស្វែងរកឱកាសដើម្បីបម្រើអ្នកដទៃ ?

ខេធី ជាក្មេងស្រីក្នុងថ្នាក់កុមារបានបង្រៀនយើង កាលដែលយើងបានឃើញពីឥទ្ធិពលរបស់នាងលើគ្រួសារនាង ។ នាងបានចូលរួមក្នុងថ្នាក់កុមារ ហើយបានទាក់ចិត្តទៅនឹងការបង្រៀននៃដំណឹងល្អ ។ ជាមួយនឹងជំនឿ និងទីបន្ទាល់ដ៏លូតលាស់ ខេធី បានទុកលិខិតតូចមួយក្រោមខ្នើយប៉ាម៉ាក់នាង ។ នាងបានសរសេរថា សេចក្តីពិតនៃដំណឹងល្អបានក្លាយទៅជា « ផ្ទះនៅក្នុងដួងចិត្តរបស់នាង » ។ នាងបានចែកចាយនូវបំណងប្រាថ្នារបស់នាងក្នុងការខិតទៅជិតព្រះវរបិតាសួគ៌របស់នាង ក្នុងការគោរពតាមបទបញ្ញត្តរបស់ទ្រង់ និងក្នុងការឲ្យគ្រួសាររបស់នាងបានផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធ ។ ទីបន្ទាល់ដ៏សាមញ្ញរបស់កូនស្រីដ៏ផ្អែមល្ហែមរូបនេះបានដក់ជាប់នៅក្នុងដួងចិត្តប៉ាម៉ាក់នាង នៅក្នុងរបៀបដ៏មានអានុភាពមួយ ។ ខេធី និងគ្រួសាររបស់នាងពិតជាបានទទួលនូវពិធីការពិសិដ្ឋនៃព្រះវិហារបរិសុទ្ធដែលចងភ្ជាប់ក្រុមគ្រួសាររបស់គេជាមួយគ្នាជារៀងរហូត ។ ដួងចិត្តដ៏ជឿជាក់ និងគំរូនៃសេចក្តីជំនឿរបស់ ខេធី បានជួយនាំមកនូវពរជ័យដ៏អស់កល្បដល់គ្រួសារនាង ។ តើទីបន្ទាល់ដ៏ស្មោះត្រង់ និងបំណងប្រាថ្នាដើម្បីធ្វើតាមផែនការព្រះអម្ចាស់ អាចនាំយើងឲ្យឃើញកាន់តែច្បាស់នូវអ្វីដែលសំខាន់បំផុតដែរឬទេ ?

គ្រួសាររបស់យើង កំពុងរៀនពីសាច់ញាតិដ៏ជិតស្និទ្ធម្នាក់ គឺ លីអាម អាយុប្រាំមួយឆ្នាំ ។ ឆ្នាំមុននេះ លីអាម បានប្រឈមមុខនឹងជំងឺមហារីកខួរក្បាលដ៏កាចសាហាវ ។ បន្ទាប់ពីការវះកាត់ដ៏លំបាកពីរដង គេបានសម្រេចថា ការព្យាបាលដោយកាំរស្មីគឺចាំបាច់ផងដែរ ។ អំឡុងពេលនៃការព្យាបាលទាំងនេះ គេតម្រូវឲ្យ លីអាម នៅតែម្នាក់ឯង ហើយត្រូវដេកឲ្យស្ងៀមមិនកម្រើកសោះតែម្តង ។ លីអាម មិនចង់ទទួលថ្នាំម្ញាប់ការឈឺចាប់នោះទេ ព្រោះគាត់មិនចូលចិត្តអារម្មណ៍ដែលគាត់ទទួលពីថ្នាំនោះទេ ។ គាត់បានសម្រេចចិត្តថា បើសិនគាត់គ្រាន់តែអាចឮសម្លេងប៉ារបស់គាត់កំឡុងពេលព្យាបាលនោះ គាត់នឹងគេងនៅស្ងៀម ដោយមិនចាំបាច់មានថ្នាំម្ញាប់ការឈឺចាប់នោះទេ ។

ក្នុងពេលដ៏រសាប់រសល់ទាំងនេះ ប៉ារបស់គាត់បាននិយាយទៅកាន់គាត់នូវពាក្យលើកទឹកចិត្ត និងសេចក្តីស្រឡាញ់ថា « លីអាម ទោះបីជាកូនមិនបានឃើញប៉ា ប៉ុន្តែប៉ានៅទីនេះទេ ។ ប៉ាដឹងថាកូនអាចធ្វើវាបាន ។ ប៉ាស្រឡាញ់កូន » ។ លីអាម បានទទួលការព្យាបាលដោយកាំរស្មីចំនួន 33 ដង ដោយជោគជ័យ ដោយនៅស្ងៀមមិនកម្រើកសោះឡើយ វាជាការសម្រេចមួយ ដែលគ្រូពេទ្យបានគិតថា វាមិនអាចទៅរួចដោយគ្មានថ្នាំម្ញាប់ការឈឺចាប់នោះទេសម្រាប់កូនក្មេងម្នាក់ ។

ដោយឆ្លងកាត់ការឈឺចាប់ និងការលំបាកជាច្រើនខែមក សុទិដ្ឋិនិយមរបស់ លីអាម បានក្លាយជាគំរូដ៏អស្ចារ្យមួយក្នុងការប្រឈមមុខនឹងគ្រោះថ្នាក់ដោយក្តីសង្ឃឹម និងក្តីរីករាយ ។ គ្រូពេទ្យ គិលានុបដ្ឋាយិកា និងអ្នកផ្សេងទៀតរាប់មិនអស់ ត្រូវបានបំផុសដោយក្តីក្លាហានរបស់ លីអាម ។

យើងទាំងអស់គ្នាកំពុងរៀននូវមេរៀនដ៏សំខាន់ពី លីអាម --- ជាមេរៀនពីការជ្រើសរើសសេចក្តីជំនឿ និងការទុកចិត្តលើព្រះវរបិតាសួគ៌របស់យើង ។ ដូចជា លីអាម ដែរ យើងមិនអាចមើលឃើញព្រះវរបិតារបស់យើងទេ ប៉ុន្តែយើងអាចស្តាប់សម្លេងទ្រង់ ដើម្បីផ្តល់ឲ្យយើងនូវកម្លាំងដែលយើងត្រូវការ ដើម្បីស៊ូទ្រាំឧបសគ្គក្នុងជីវិត ។ តើគំរូរបស់លីអាមអាចជួយយើងឲ្យកាន់តែយល់ច្បាស់ពីព្រះបន្ទូលរបស់ស្តេច បេនយ៉ាមីន ពីការក្លាយដូចជាកូនក្មេង ---ដែលងាយប្រដៅ ស្លូតបូត រាបសា អត់ឱន និងពោរពេញដោយសេចក្តីស្រឡាញ់ដែរឬទេ ? ( សូមមើល ម៉ូសាយ 3:19 ) ។

ក្មេងៗទាំងនេះ កំពុងផ្តល់នូវគំរូនៃលក្ខណៈដូចជាកូនក្មេង ដែលយើងត្រូវអភិវឌ្ឍ និងរកឲ្យឃើញឡើងវិញនៅក្នុងខ្លួនយើង ដើម្បីចូលទៅក្នុងនគរស្ថានសួគ៌ ។ ពួកគេជាវិញ្ញាណដ៏បរិសុទ្ធ ដែលមិនត្រូវបានប្រឡាក់ដោយលោកិយ ---ពួកគេងាយស្រួលបង្រៀន និងពេញដោយសេចក្តីជំនឿ ។ គ្មានការសង្ស័យទេថា ព្រះអង្គសង្គ្រោះមាននូវសេចក្តីស្រឡាញ់ និងការពេញចិត្តយ៉ាងពិសេសចំពោះក្មេងតូចៗទាំងនេះ ។

ក្នុងព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងឡាយនៃការយាងមកកាន់ទ្វីបអាមេរិករបស់ព្រះអង្គសង្គ្រោះ ការបម្រើដ៏ទន់ភ្លន់របស់ទ្រង់ចំពោះក្មេងតូចៗ គឺលេចធ្លោតែម្តង ។ ទ្រង់បានឈោងទៅក្មេងម្នាក់ៗ ដោយទន់ភ្លន់ ។

« ហើយទ្រង់បានយកកូនក្មេងរបស់ពួកគេ ម្តងម្នាក់ៗ ហើយបានប្រទានពរដល់ពួកវា ហើយបានអធិស្ឋានដល់ព្រះវរបិតាសម្រាប់ពួកវា ។ ហើយកាលទ្រង់បានធ្វើការនេះចប់ហើយ នោះទ្រង់ក៏ព្រះកន្សែង ។ ...

« ហើយទ្រង់មានព្រះបន្ទូលទៅហ្វូងមនុស្សថា ៖ មើលន៍ កូនតូចៗរបស់អ្នករាល់គ្នា » ( នីហ្វៃទី3 17:21—23 ) ។

អែលឌើរ អិម រ័សុល បាឡឺដ បានបង្រៀនយើងពីសារៈសំខាន់នៃដំបូន្មានរបស់ព្រះអង្គសង្គ្រោះឲ្យ « មើល កូនតូចៗរបស់អ្នករាល់គ្នា » ពេលលោកបានមានប្រសាសន៍ថា « សូមកត់សម្គាល់ថា ទ្រង់មិនបានមានបន្ទូលថា ‹ ចូរក្រឡេកមើលពួកគេ › ឬ ‹ ចូរសង្កេតពួកគេធម្មតាៗ › ឬ ‹ ចូរមើលពួកគេម្តងម្កាលចំពោះទិសដៅទូទៅរបស់គេ › នោះឡើយ ។ ទ្រង់បានមានបន្ទូលថា *មើល* ពួកគេ ។ ចំពោះខ្ញុំ នោះមានន័យថា យើងគួរឱបក្រសោបគេដោយកែវភ្នែក និងដួងចិត្តយើង យើងគួរមើល និងពេញចិត្តពួកគេចំពោះការពិតថាពួកគេគឺជា ៖ កូនៗវិញ្ញាណរបស់ព្រះវរបិតាសួគ៌នឹង លក្ខណៈដ៏ទេវភាព » ( « Great Shall Be the Peace of Thy Children » *Ensign* ខែ មេសា ឆ្នាំ 1994 ទំព័រ 59 ) ។

គ្មានកន្លែងណាដែលល្អជាងក្នុងគ្រួសាររបស់យើងទេ ក្នុងការ « មើល កូនតូចៗរបស់យើង » ។ ផ្ទះជាកន្លែងដែលយើងអាចរៀន និងលូតលាស់ជាមួយគ្នា ។ ចម្រៀងកុមារដ៏ពីរោះមួយរបស់យើង បង្រៀនពីសេចក្តីពិតនេះថា ៖

*ព្រះប្រទានយើងនូវគ្រួសារ*
*ដើម្បីជួយយើងក្លាយជាអ្វីដែលទ្រង់ចង់ឲ្យយើងក្លាយជា —*
*នេះជារបៀបទ្រង់ចែកចាយសេចក្តីស្រឡាញ់ទ្រង់*
*ត្បិតគ្រួសារគឺមកពីព្រះ ។*

គឺនៅទីនេះ ក្នុងគ្រួសាររបស់យើងនេះហើយ នៅក្នុងបរិយាកាសនៃក្តីស្រឡាញ់ ដែលយើងមើលឃើញ និងពេញចិត្ត ចំពោះលក្ខណៈដ៏ទេវភាពនៃកូនៗវិញ្ញាណរបស់ទ្រង់ ក្នុងរបៀបដ៏កាន់តែផ្ទាល់ខ្លួន ។ គឺនៅទីនេះ ក្នុងគ្រួសាររបស់យើងនេះហើយ ដែលដួងចិត្តយើង អាចត្រូវបានបន្ទន់ ហើយនៅក្នុងការបន្ទាបខ្លួន នោះយើងមានបំណងប្រាថ្នាដើម្បីផ្លាស់ប្តូរ ឲ្យកាន់តែដូចជាកូនក្មេង ។ នេះជាដំណើរការមួយ ដែលយើងអាចក្លាយកាន់តែដូចជាគ្រីស្ទ ។

តើបទពិសោធន៍ជីវិតមួយចំនួនបានយកនូវដួងចិត្តជឿជាក់ និងជំនឿដូចកូនក្មេងដែលអ្នកធ្លាប់មានចេញពីអ្នកដែរឬទេ ? សូមក្រឡេកមើលទៅកូនក្មេងនៅក្នុងជីវិតរបស់អ្នក ។ ហើយមើលម្តងទៀត ។ ពួកគេអាចជាកូនក្មេងនៅក្នុងគ្រួសារអ្នក ក្មេងៗនៅតាមផ្លូវ ឬនៅក្នុងថ្នាក់បឋមសិក្សាក្នុងវួដរបស់អ្នក ។ បើយើងមានដួងចិត្តចង់រៀន និងមានឆន្ទៈដើម្បីធ្វើតាមគំរូនៃក្មេងៗ នោះលក្ខណៈដ៏ទេវភាពរបស់គេ អាចជាកូនសោដើម្បីចាក់បើកការលូតលាស់ខាងវិញ្ញាណរបស់យើង ។

ខ្ញុំតែងតែមានអំណរគុណ សម្រាប់ពរជ័យនៃកូនៗរបស់ខ្ញុំផ្ទាល់ ។ គំរូរបស់គេម្នាក់ៗ បានបង្រៀនខ្ញុំនូវមេរៀនដែលខ្ញុំត្រូវការ ។ ពួកគេបានជួយខ្ញុំឲ្យផ្លាស់ប្តូរកាន់តែប្រសើរឡើង ។

ខ្ញុំថ្លែងទីបន្ទាល់ដ៏រាបសា និងពោរពេញដោយភាពច្បាស់លាស់របស់ខ្ញុំថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។ ទ្រង់ជាបុត្រាដ៏ល្អឥតខ្ចោះ --ងាយប្រដៅ ស្លូតបូតទាបរាបសា អត់ឱន និងពោរពេញដោយសេចក្តីស្រឡាញ់ ។ សូមឲ្យយើងម្នាក់ៗ មានដួងចិត្តធ្វើតាមគំរូរបស់ទ្រង់ ដើម្បីក្លាយដូចជាកូនក្មេង តូចៗ ហើយដោយរបៀបនោះ យើងអាចត្រឡប់ទៅផ្ទះនៅឯស្ថានសួគ៌របស់យើងវិញ ខ្ញុំអធិស្ឋាននៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។